ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ ខេត្តកណ្ដាល

សៀវភៅ

# ការគ្រប់គ្រងសាលារៀន






## វិទ្យាល័យ សម្តេចអគ្គមហាសេនាបតី

## តេជោ ហ៊ុន សែន ព្រែកតាទែន

សម្រាប់ឆ្នាំ២០២១

## ១ គោលបំណង

វត្ថុបំណងនៃការរៀបចំសៀវភៅនេះ គឺសម្រាប់បង្ហាញដល់មាតាបិតាសិស្ស និងសហគមន៍ទាំងមូលអំពីគណនេយ្យភាព និងការយកចិត្តទុកដាក់ខ្ពស់របស់លោកគ្រូអ្នកគ្រូ ប្រធានក្រុមបច្ចេកទេស និងគណៈនាយកក្នុងការអនុវត្តកិច្ចការតាម **តួនាទីនិងមុខតំណែង** នៃយន្តការនិងប្រព័ន្ធដឹកនាំគ្រប់គ្រងរបស់សាលារៀនសហគមន៍ ដើម្បីធ្វើយ៉ាងណាឱ្យសាលារៀន បានផ្តល់សេវាអប់រំប្រកបដោយប្រសិទ្ធភាពដល់កូនចៅ និងតាមតម្រូវការរបស់សហគមន៍។

## ២ សារៈសំខាន់

សៀវភៅការគ្រប់គ្រងសាលារៀន គឺមានរៀបរាប់អំពី **កិច្ចការសំខាន់ៗដែលប្រព្រឹត្តទៅជាប្រចាំក្នុងសាលារៀន** ក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀន ដើម្បីធានាបាននៅដំណាច់ឆ្នាំសិក្សានីមួយៗ សាលារៀននឹងសម្រេចជាសាលារៀនមានប្រសិទ្ធភាព។ កិច្ចការសំខាន់ៗទាំងនេះជាមូលដ្ឋានដើម្បីបន្សុី និងភ្ជាប់ទៅនឹង **តួនាទីនិងមុខតំណែង** ដែលជាភារកិច្ចប្រចាំថ្ងៃជាក់ស្តែង របស់គ្រូមុខវិជ្ជា គ្រូបន្ទុកថ្នាក់ ប្រធានក្រុមមុខវិជ្ជា នាយករង និងនាយកសាលារៀន។

ដូច្នេះការរៀបចំយន្តការ និងរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងសាលរៀន គឺផ្អែកលើការវិភាគលម្អិតអំពីតួនាទីនិងមុខតំណែង និងសម្រាប់ភ្ជាប់ទៅនឹងការធ្វើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងការធ្វើស្វ័យវាយតម្លៃលទ្ធផលប្រចាំឆ្នាំផងដែរ។

## ៣ អំពីលទ្ធផលរំពឹងទុកប្រចាំឆ្នាំរបស់សាលារៀន

សាលារៀនបានជាប់ស្តង់ដា ជាសាលារៀនមានប្រសិទ្ធភាពចំនួន១ឆ្នាំកន្លងមកហើយ គឺឆ្នាំសិក្សា២០១៩-២០២០។ ដូច្នេះនៅក្នុងឆ្នាំសិក្សា២០២០-២០២១នេះ សាលារៀនប្តេជ្ញានឹងសម្រេចឱ្យបានស្តង់ដាសាលារៀនមានប្រសិទ្ធភាពជាបន្តទៀត ទោះបីសាលារៀនជួបនឹងស្ថានភាពកូវីដ-១៩ក៏ដោយ តែសាលារៀនបានបម្លែងការប្រឈមទាំងនេះ ឱ្យទៅជាឱកាសសម្រាប់អនុវត្តការគ្រប់គ្រងតាមសាលារៀន ក្នុងបរិបទថ្មីវិញ។

ដូច្នេះនៅចុងឆ្នាំសាលារៀនប្តេជ្ញាចិត្តបង្កើន៖

ក. **លទ្ធផលប្រមូលសិស្សចូលរៀន៖** *ចំនួនសិស្សចូលរៀន* ..៨៣៨នាក់

ខ. **លទ្ធផលជួយសិស្សឱ្យបានរៀនបន្ត៖** *ចំនួនសិស្សបោះបង់ ១០នាក់*

គ. **លទ្ធផលសិស្សរៀនបានលទ្ធផលល្អ និងល្អប្រសើរ៖** *ចំនួនសិស្សបាននិទ្ទេសA២០%. ១៦៨នាក់ B៥០%.៤១៩នាក់ និងC៣០%.២៥១នាក់*

## ៤ អំពីកិច្ចការដែលប្រព្រឹត្តទៅជាប្រចាំក្នុងសាលារៀន

ដើម្បីអាចធានាបានសាលារៀនជាប់ស្តង់ដា ជាសាលារៀនមានប្រសិទ្ធភាព នៅក្នុងឆ្នាំសិក្សា២០២១នេះ សាលារៀនបានកំណត់កិច្ចការជាអាទិភាពមួយចំនួន សម្រាប់បែងចែកឱ្យមានការទទួលខុសត្រូវទៅតាមភារកិច្ច របស់គ្រូបង្រៀន គ្រូបន្ទុកថ្នាក់ ប្រធានក្រុមបច្ចេកទេស នាយករង និងនាយកសាលារៀន។

## កិច្ចការទទួលខុសត្រូវផ្ទាល់របស់គ្រូមុខវិជ្ជា និងគ្រូបន្ទុកថ្នាក់ (មាន១០)

១. ធ្វើបំណែងចែកកម្មវិធីសិក្សាបង្រៀនប្រចាំសប្ដាហ៍សម្រាប់ឆ្នាំសិក្សា៖ *(ផ្អែកលើកម្មវិធីសិក្សាលម្អិតអប់រំមូលដ្ឋានចំណេះទូទៅ)*

២. ធ្វើផែនការនិងរបាយការណ៍បង្រៀន៣ឆ្នាំ និង១ឆ្នាំ *(ផ្អែកលើលទ្ធផលតេស្តស្តង់ដាដើមឆ្នាំ)*

៣. ធ្វើផែនការនិងរបាយការណ៍បង្រៀនរៀងរាល់៣ខែ *(ផ្អែកលើផែនការបង្រៀន១ឆ្នាំ និង៣ឆ្នាំ)*

៤. រៀបចំគម្រោងបង្រៀនមួយមេរៀនមានច្រើនម៉ោងសិក្សា

*(ផ្ដោតលើចំណេះដឹងមុខវិជ្ជា៖ ឱ្យបានគ្រប់មេរៀនទាំងអស់ ដែលមានក្នុងកម្មវិធីសិក្សាលម្អិត រួមជាមួយសៀវភៅសិក្សាគោល)*

៥. រៀបចំគម្រោងបង្រៀនចម្រុះមុខវិជ្ជា

*(ផ្ដោតលើបំណិនជីវិត និងបំណិនការងារ៖តាមរយៈកិច្ចការគម្រោងដោយផ្សារភ្ជាប់បំណិនរកចំណូល)*

៦. បង្កើតក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន *(សម្រាប់ដឹកនាំគ្រប់គ្រងទិន្នន័យរដ្ឋបាលថ្នាក់រៀន រួមជាមួយទិន្នន័យហឹង្សា និងទិន្នន័យការរៀនរបស់សិស្សម្នាក់ៗ និងការបង្រៀនរបស់គ្រូម្នាក់ៗ)*

៧. ជួយសិស្សម្នាក់ៗ ឱ្យធ្វើផែនការសិក្សាឆ្នាំ និងរបាយការណ៍សិក្សាប្រចាំខែ *(ផ្អែកលើលទ្ធផលតេស្តស្តង់ដាដើមឆ្នាំ)*

៨. បង្កើតគណៈកម្មការគ្រប់គ្រងថ្នាក់រៀន *(ផ្ដោតលើលទ្ធផលសិក្សារបស់សិស្សម្នាក់ៗ និងកែលម្អថ្នាក់រៀន)*

៩. លប់បំបាត់អំពើហឹង្សា *(នៅថ្នាក់រៀន សាលារៀន និងគ្រួសារសិស្ស)*

១០. សរសេរករណីសិក្សាសិស្ស *(ផ្ដោតលើសិស្សស្រី ពិការ ជនជាតិដើមភាគតិច រៀនយឺត មកពីគ្រួសារជួបការលំបាក មករៀនយឺត អវត្តមានច្រើន បម្រុងបោះបង់ការសិក្សា ឬបានបោះបង់ការសិក្សា)*

## កិច្ចការទទួលខុសត្រូវផ្ទាល់របស់នាយករង និងនាយក (មាន៨)

១. លទ្ធផលការងារក្រុមប្រឹក្សាកុមារយុវជន៖ *ថ្នាក់រៀន និងសាលារៀន*

២. លទ្ធផលការងារតេស្តស្តង់ដាកម្រិតសាលារៀន៖ *ដើមឆ្នាំ ប្រចាំខែ និងដំណាច់ឆមាស*

៣. លទ្ធផលការងារគណៈកម្មការគ្រប់គ្រងសាលារៀន៖ *រួមជាមួយគណៈកម្មការគ្រប់គ្រងថ្នាក់រៀន*

៤. លទ្ធផលការងារផែនការកែលម្អសាលារៀន៖ *រួមជាមួយផែនការកែលម្អថ្នាក់រៀន*

៥. លទ្ធផលការងារកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ៖ *គ្រូបង្រៀន នាយករង និងនាយក*

៦. លទ្ធផលការងារប្រជុំពិនិត្យតាមដាន៖ *ប្រចាំខែ និងត្រីមាស*

៧. លទ្ធផលការងារអធិការកិច្ច៖ *ការបង្រៀនរបស់គ្រូមុខវិជ្ជា និងការគ្រប់គ្រងរដ្ឋបាលថ្នាក់រៀនរបស់គ្រូបន្ទុកថ្នាក់*

៨. លទ្ធផលការងារស្វ័យវាយតម្លៃលទ្ធផលប្រចាំឆ្នាំ៖ *គ្រូបង្រៀន នាយករង និងនាយក*

# ៥ អំពីរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងសាលារៀន

**នាយក**
ឈ្មោះ ប្រាក់ វុទ្ធី

លេខា
ឈ្មោះ យស សុគន្ធានី

គ្រូIT
ឈ្មោះ អ៊ឹម ចន្ថា

**នាយករងរដ្ឋបាល**
ឈ្មោះ កុយ ធី

**នាយករងបច្ចេកទេស**
ឈ្មោះ ចាន់ ស្រីដា

### គ្រូបន្ទុកថ្នាក់

លោក ឈាង សុវណ្ណី ថ្នាក់ទី 7A
លោកស្រី ដឹម សុខលី ថ្នាក់ទី 7B
លោក វិន សុខជា ថ្នាក់ទី 7C
លោកស្រី ស្រ៊ុន សុខាវ័ត្ន ថ្នាក់ទី 7D
លោក ម៉ៅ ច័ន្ទដា ថ្នាក់ទី 8A
លោក នៅ ផុន ថ្នាក់ទី 8B
លោក ឡុច នឿន ថ្នាក់ទី 8C
លោក វ៉ន មេត្រី ថ្នាក់ទី 9A
លោកស្រី គ្រី សុភ័ក្រ្ត ថ្នាក់ទី 9B
លោក ម៉ម សៅភីរិទ្ធិ ថ្នាក់ទី 9C
លោកស្រី គឹង កុម្ភៈនី ថ្នាក់ទី10A
លោកស្រី អ៊ុំ សុជា ថ្នាក់ទី10B
លោក ក មុនី ថ្នាក់ទី10C
លោកស្រី ពេជ្រ កត្តា ថ្នាក់ទី11A
លោក លី សារី ថ្នាក់ទី11B
លោកស្រី ប៉ាន ច័ន្ទសុនីតា ថ្នាក់ទី11C
លោកស្រី យឹម សូនី ថ្នាក់ទី12A
លោកស្រី ហាន សាវន ថ្នាក់ទី12B
លោក ភួង ថារិទ្ធិ ថ្នាក់ទី12C

### គ្រូទីចាត់ការ

លោក ចែម យូដេត (យុវជន)
លោក វ៉ន ភត្រា (បណ្ណារក្ស)
លោក ប៊ិច ពណ្ណវរៈ (បណ្ណារក្ស)
លោក គឹម ដារឿន (គណនេយ្យ)
លោកស្រី សុខ ស្រីល័ក្ខ(បន្ទប់ពិសោធន៍)
លោកស្រី ពិន ដោត្យាវ៉ាមី(បន្ទប់ពិសោធន៍)

### ឈ្មោះគ្រូមុខវិជ្ជា.ភាសាខ្មែរ

លោកស្រី ហាន សាវន ថ្នាក់ទី10.11.12
លោកស្រី គឹង កុម្ភៈនី ថ្នាក់ទី10.11.12
លោកស្រី សំ ស៊ីណា ថ្នាក់ទី9
លោក ភួង ថារិទ្ធិ ថ្នាក់ទី10.11.12
លោក ម៉ៅ ច័ន្ទដា ថ្នាក់ទី7
លោក ឈាង សុវណ្ណី ថ្នាក់ទី8
លោក វ៉ន និមល ថ្នាក់ទី8
លោក វិន សុខជា ថ្នាក់ទី7

### ឈ្មោះគ្រូមុខវិជ្ជា.ប្រវត្តិ.ភូមិ

លោក ស៊ីម ពិសី ថ្នាក់ទី11.12
លោក តាំង សាមីត ថ្នាក់ទី10.11.12
លោក នៅ ផុន ថ្នាក់ទី8
លោកស្រី ផុន ចាន់ធឿន ថ្នាក់ទី7
លោកស្រី ផុន ស្រីមុំ ថ្នាក់ទី9.10

### ឈ្មោះគ្រូមុខវិជ្ជា.សីលធម៌.ពលរដ្ឋ

លោក សេង ប៊ុនថន ថ្នាក់ទី9.12
លោក លី សារី ថ្នាក់ទី8.11
លោក ឡុច នឿន ថ្នាក់ទី7.8
លោកស្រី អ៊ុំ សុជា ថ្នាក់ទី10

### ឈ្មោះគ្រូមុខវិជ្ជា.ភាសាបរទេស

លោក ស៊ុន សុភាព ថ្នាក់ទី8.12
លោក ផុង តាំងឡេង ថ្នាក់ទី11.12
លោកស្រី គ្រី សុភ័ក្រ្ត ថ្នាក់ទី9
លោកស្រី ប៉ាន ច័ន្ទសុនីតា ថ្នាក់ទី10
លោកស្រី ដឹម សុខលី ថ្នាក់ទី7

### ឈ្មោះគ្រូមុខវិជ្ជា.គណិតវិទ្យា

លោកស្រី ស្រ៊ុន សុខាវ័ត្ន ថ្នាក់ទី7.11
លោកស្រី គង់ ពុទ្ធារ៉ា ថ្នាក់ទី8.10
លោក កែន សុវណ្ណរិទ្ធិ ថ្នាក់ទី12
លោក ក មុនី ថ្នាក់ទី9.10
លោក សៀក ណារិទ្ធិ ថ្នាក់ទី8.11
លោក ម៉ែន រិទ្ធី ថ្នាក់ទី9
លោក ជិន សុភា ថ្នាក់ទី8
លោក ហុន សេងហន ថ្នាក់ទី7

### ឈ្មោះគ្រូមុខវិជ្ជា.រូបវិទ្យា.គីមីវិទ្យា

លោកស្រី ថោង សុជាតិ ថ្នាក់ទី11.12
លោកស្រី ញ៉ែម រំលង ថ្នាក់ទី11.12
លោកស្រី លី វាសនា ថ្នាក់ទី9.10
លោកស្រី ធឹង ចាន់ធឿន ថ្នាក់ទី7
លោកស្រី សយ ពុធពិសី ថ្នាក់ទី8

### ឈ្មោះគ្រូមុខវិជ្ជា.ជីវវិទ្យា.ផែនដីវិទ្យា

លោកស្រី យឹម សូនី ថ្នាក់ទី11.12
លោកស្រី ម៉ក់ ភក្តី ថ្នាក់ទី7.8
លោកស្រី ប៉ូច កញ្ញា ថ្នាក់ទី9
លោកស្រី ចែម រ៉ានី ថ្នាក់ទី10.12
លោកស្រី សំ សុជា ថ្នាក់ទី11.12
លោក វ៉ន មេត្រី ថ្នាក់ទី7.8.9

### ឈ្មោះគ្រូមុខវិជ្ជា.អប់រំកាយ.សេដ្ឋកិច្ច

លោក ម៉ម សៅភីរិទ្ធិ ថ្នាក់ទី7.8
លោក សំ ប៊ុណ្ណរិទ្ធិ ថ្នាក់ទី11.12

# ៦ អំពីការពិពណ៌នាអំពីតួនាទី និងមុខតំណែង

(Job Description)

ខាងក្រោមនេះ ជាការពិពណ៌នាតួនាទី និងមុខតំណែងរបស់នាយក និងរបស់គ្រូបង្រៀន។ ចំពោះនាយកមានបែងចែកលម្អិត សម្រាប់នាយក នាយករងរដ្ឋបាល និងនាយករងបច្ចេកទេស។ ចំពោះគ្រូបង្រៀនមានបែងចែកលម្អិត សម្រាប់គ្រូមុខវិជ្ជា និងគ្រូបន្ទុកថ្នាក់។

## គណៈនាយក

### I. កិច្ចការរបស់នាយកសាលារៀន

ជានាឱ្យសាលារៀនសម្រេចស្តង់ដា ជាសាលារៀនមានប្រសិទ្ធភាព

ក. លទ្ធផលប្រមូលសិស្សចូលរៀន៖ *ចំនួនសិស្សចូលរៀន*

ខ. លទ្ធផលជួយសិស្សឱ្យបានបន្តរៀន៖ *ចំនួនសិស្សបោះបង់*

គ. លទ្ធផលសិស្សរៀនបានលទ្ធផលល្អ និងល្អប្រសើរ៖ *ចំនួនសិស្សបាននិទ្ទេសA២០% B៥០% និងC៣០%*

### II. កិច្ចការរបស់នាយករងបច្ចេកទេសសាលារៀន

១. លទ្ធផលការងារក្រុមប្រឹក្សាកុមារយុវជន៖ *ថ្នាក់រៀន និងសាលារៀន*

២. លទ្ធផលការងារតេស្តស្តង់ដាកម្រិតសាលារៀន៖ *ដើមឆ្នាំ ប្រចាំខែ និងដំណាច់ឆមាស*

៦. លទ្ធផលការងារប្រជុំពិនិត្យតាមដាន៖ *ប្រចាំខែ និងត្រីមាស*

៧. លទ្ធផលការងារអធិការកិច្ច៖ *ការបង្រៀនរបស់គ្រូមុខវិជ្ជា និងការគ្រប់គ្រងរដ្ឋបាលថ្នាក់រៀនរបស់គ្រូបន្ទុកថ្នាក់*

### III. កិច្ចការរបស់នាយករងរដ្ឋបាលសាលារៀន

៣. លទ្ធផលការងារគណៈកម្មការគ្រប់គ្រងសាលារៀន៖ *រួមជាមួយគណៈកម្មការគ្រប់គ្រងថ្នាក់រៀន*

៤. លទ្ធផលការងារផែនការកែលម្អសាលារៀន៖ *រួមជាមួយផែនការកែលម្អថ្នាក់រៀន*

៥. លទ្ធផលការងារកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ៖ *គ្រូបង្រៀន នាយករង និងនាយក*

៨. លទ្ធផលការងារស្វ័យវាយតម្លៃលទ្ធផលប្រចាំឆ្នាំ៖ *គ្រូបង្រៀន នាយករង និងនាយក*

## គ្រូបង្រៀន

### I. កិច្ចការរបស់គ្រូបន្ទុកថ្នាក់

១. បង្កើតក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន
*(សម្រាប់ដឹកនាំគ្រប់គ្រងទិន្នន័យរដ្ឋបាលថ្នាក់រៀន រួមជាមួយទិន្នន័យអំពើហឹង្សា និងទិន្នន័យលទ្ធផលសិក្សាសិស្សម្នាក់ៗ និងការបង្រៀនរបស់គ្រូម្នាក់ៗ)*

២. ជួយសិស្សម្នាក់ៗ ឱ្យធ្វើផែនការសិក្សាឆ្នាំ និងរបាយការណ៍សិក្សាប្រចាំខែ
*(ផ្អែកលើលទ្ធផលតេស្តស្តង់ដាដើមឆ្នាំ)*

៣. បង្កើតគណៈកម្មការគ្រប់គ្រងថ្នាក់រៀន
*(ផ្តោតលើលទ្ធផលសិក្សារបស់សិស្សម្នាក់ៗ និងកែលម្អថ្នាក់រៀន)*

៤. លប់បំបាត់អំពើហឹង្សា
*(នៅថ្នាក់រៀន សាលារៀន និងគ្រួសារសិស្ស)*

៥. សរសេរកេណើសិក្សាសិស្ស*(ផ្តោតលើសិស្សស្រី ពិការ ជនជាតិដើមភាគតិច រៀនយឺត មកពីគ្រួសារជួបការលំបាក មករៀនយឺត អវត្តមានច្រើន បម្រុងបោះបង់ការសិក្សា ឬបានបោះបង់ការសិក្សា)*

### II. កិច្ចការរបស់គ្រូមុខវិជ្ជា

១. ធ្វើបំណែងចែកកម្មវិធីសិក្សាបង្រៀនប្រចាំសប្តាហ៍សម្រាប់ឆ្នាំសិក្សា ៖*(ផ្អែកលើកម្មវិធីសិក្សាលម្អិតអប់រំមូលដ្ឋានចំណេះទូទៅ)*

២. ធ្វើផែនការនិងរបាយការណ៍បង្រៀន៣ឆ្នាំ និង១ឆ្នាំ ៖*(ផ្អែកលើលទ្ធផលតេស្តស្តង់ដាដើមឆ្នាំ)*

៣. ធ្វើផែនការនិងរបាយការណ៍បង្រៀនរៀងរាល់៣ខែ ៖*(ផ្អែកលើផែនការបង្រៀន១ឆ្នាំ និង៣ឆ្នាំ)*

៤. រៀបចំគម្រោងបង្រៀនមួយមេរៀនមានច្រើនម៉ោងសិក្សា៖
*(ផ្តោតលើចំណេះដឹងមុខវិជ្ជា៖ ឱ្យបានគ្រប់មេរៀន ដែលមានក្នុងកម្មវិធីសិក្សាលម្អិត រួមជាមួយសៀវភៅសិក្សាគោល)*

៥. រៀបចំគម្រោងបង្រៀនចម្រុះមុខវិជ្ជា ៖
*(ផ្តោតលើបំណិនជីវិត និងបំណិនការងារ៖តាមរយៈកិច្ចការគម្រោងដោយផ្សារភ្ជាប់បំណិនរកចំណូល)*

## ៧ គម្រូឧទាហរណ៍

## ការពិពណ៌នាតួនាទី និងមុខតំណែង

**ការពិពណ៌នាអំពីតួនាទី និងមុខតំណែង នាយកសាលារៀន**

(Job Description)

ឈ្មោះតួនាទី ប្រាក់ វុទ្ធី នាយកវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ព្រែកតាទែន

រាយការណ៍ទៅ ហ៊ុយ សុខា ប្រធានការិយាល័យមធ្យមសិក្សា នៃមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត កណ្តាល

ក **តួនាទី** (Main purpose of the job)

នាយកសាលារៀនជួយនាយករង ធ្វើការជាមួយប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនជួយសិស្សឱ្យចូលរៀនអស់ សិស្សរៀនចេះ និងសិស្សរៀនចប់ និងជាពិសេសដើម្បីអភិវឌ្ឍសាលារៀន ឱ្យអភិវឌ្ឍសាលារៀនឆ្លើយតបទៅនឹង ស្តង់ដាសាលារៀនមានប្រសិទ្ធិភាព។

ខ **គណនេយ្យភាពការងារ ឬកិច្ចការទទួលខុសត្រូវ** (Key Accountabilities)

**ធានាឱ្យសាលារៀនសម្រេចស្តង់ដា ជាសាលារៀនមានប្រសិទ្ធភាព**

ក. **ប្រមូលសិស្សចូលរៀន៖** *ចំនួនសិស្សចូលរៀន*

ខ. **ជួយសិស្សឱ្យបានបន្តរៀន៖** *ចំនួនសិស្សបោះបង់*

គ. **សិស្សរៀនបានលទ្ធផលល្អ និងល្អប្រសើរ៖** *ចំនួនសិស្សបាននិទ្ទេសA២០% B៥០% និងC៣០%*

គ **លទ្ធផលការបំពេញការងារ** (Key performance objectives)

| **ផលសម្រេច** (Output) | **សូនាករ នៃការបំពេញការងារ** (Key Performance Indicators) |
|---|---|
| ស្តង់ដាសាលារៀនមានប្រសិទ្ធភាព | សាលារៀនបានជាប់ស្តង់ដាចំនួន....... ក្នុងចំណោមស្តង់ដាទាំង៩/៥ |
| ក ចំនួនសិស្សចូលរៀន | សាលារៀនបានប្រមូលសិស្សចំនួន ៨៣៨ (ប្រៀបធៀបសិស្សចំនួន ៨៤១បានកំណត់ក្នុងផែនការកែលម្អសាលារៀន) |
| ខ ចំនួនសិស្សបោះបង់ | សាលារៀនបានកាត់បន្ថយសិស្សបោះបង់ចំនួន ១,៦%(ប្រៀបធៀបសិស្សចំនួន ២%បានកំណត់ក្នុងផែនការកែលម្អសាលារៀន) |
| គ លទ្ធផលសិក្សារបស់សិស្ស | **សាលារៀនបានសម្រេចចំនួនសិស្សតាមនិទ្ទេស៖**<br>Aចំនួន...........ប្រៀបធៀបចំនួនបានកំណត់ក្នុងផែនការកែលម្អសាលារៀន. 40)<br>Bចំនួន...........ប្រៀបធៀបចំនួនបានកំណត់ក្នុងផែនការកែលម្អសាលារៀន. 80)<br>Cចំនួន...........ប្រៀបធៀបចំនួនបានកំណត់ក្នុងផែនការកែលម្អសាលារៀន.116)<br>Dចំនួន...........ប្រៀបធៀបចំនួនបានកំណត់ក្នុងផែនការកែលម្អសាលារៀន.164)<br>Eចំនួន...........ប្រៀបធៀបចំនួនបានកំណត់ក្នុងផែនការកែលម្អសាលារៀន.201)<br>Fចំនួន...........ប្រៀបធៀបចំនួនបានកំណត់ក្នុងផែនការកែលម្អសាលារៀន.237) |

ឈ្មោះនាយកសាលា:. ប្រាក់ វុទ្ធី ហត្ថលេខា:.................................................................................

ឈ្មោះប្រធានការិយាល័យមធ្យមនៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកណ្តាល ហ៊ុយ សុខា ហត្ថលេខា:................................

ធ្វើនៅថ្ងៃខែឆ្នាំ:..........................................................

# ការពិពណ៌នាអំពីតួនាទី និងមុខតំណែង នាយករងបច្ចេកទេស

(Job Description)

ឈ្មោះតួនាទី　ចាន់ ស្រីជា　នាយិការងបច្ចេកទេស វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ព្រែកតាទែន

រាយការណ៍ទៅ　ប្រាក់ វុទ្ធី　នាយក វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ព្រែកតាទែន

**ក　តួនាទី** ( Main purpose of the job )

នាយករងបច្ចេកទេស ជួយប្រធានក្រុមបច្ចេកទេសមុខវិជ្ជា តាមកម្រិតថ្នាក់ ឱ្យអាចធ្វើការជាមួយគ្រូបង្រៀនមុខវិជ្ជា ដើម្បីជួយសិស្សរៀនចេះ និងសិស្សរៀនចប់ ដើម្បីរួមចំណែកសម្រេចស្តង់ដាសាលារៀនមានប្រសិទ្ធិភាព។

**ខ　គណនេយ្យភាពការងារ ឬកិច្ចការទទួលខុសត្រូវ** ( Key Accountabilities )

ក.　**លទ្ធផលការងារក្រុមប្រឹក្សាកុមារយុវជន៖** *ថ្នាក់រៀន និងសាលារៀន*

ខ.　**លទ្ធផលការងារតេស្តស្តង់ដាកម្រិតសាលារៀន៖** *ដើមឆ្នាំ ប្រចាំខែ និងដំណាច់ឆមាស*

គ.　**លទ្ធផលការងារប្រជុំពិនិត្យតាមដាន៖** *ប្រចាំខែ និងត្រីមាស*

ឃ.　**លទ្ធផលការងារអធិការកិច្ច៖** *ការបង្រៀនរបស់គ្រូមុខវិជ្ជា និងការគ្រប់គ្រងរដ្ឋបាលថ្នាក់រៀនរបស់គ្រូបន្ទុកថ្នាក់*

**គ　លទ្ធផលការបំពេញការងារ** ( Key performance objectives )

| **ផលសម្រេច** ( Output ) | **សូចនាករ នៃការបំពេញការងារ** ( Key Performance Indicators ) |
|---|---|
| **ក. លទ្ធផលការងារក្រុមប្រឹក្សាកុមារយុវជន៖** *ថ្នាក់រៀន និងសាលារៀន* | ១. ចំនួនថ្នាក់រៀនមានដំណើរការក្រុមប្រឹក្សាកុមារយុវជន ក្នុងនោះមាន៖ ការបង្កើតសិស្សក្រុមតូចចំនួន២២ក្នុងថ្នាក់រៀនមួយ ឱ្យទទួលបន្ទុកកត់ត្រាទិន្នន័យរដ្ឋបាលថ្នាក់រៀនជាប្រចាំ ដើម្បីអាចសរុប និងរាយការណ៍ប្រចាំខែ ទៅឱ្យគ្រូបន្ទុកថ្នាក់ គណៈកម្មការគ្រប់គ្រងថ្នាក់រៀន និងក្រុមប្រឹក្សាកុមារយុវជនសាលារៀន<br>២. ចំនួនខែដែលក្រុមប្រឹក្សាកុមារយុវជនសាលារៀននីមួយៗ បានធ្វើរបាយការណ៍សរុបទិន្នន័យរដ្ឋបាលពីគ្រប់ថ្នាក់រៀន ទៅឱ្យនាយករងកាន់បច្ចេកទេស និងគណៈកម្មការគ្រប់គ្រងសាលារៀន |
| **ខ.លទ្ធផលការងារតេស្តស្តង់ដាកម្រិតសាលារៀន៖** *ដើមឆ្នាំ ប្រចាំខែ និងដំណាច់ឆមាស* | ១. ចំនួនសិស្សគ្រប់កម្រិតថ្នាក់បានធ្វើតេសស្តង់ដាដើមឆ្នាំ តាមការណែនាំ<br>២. ចំនួនសិស្សគ្រប់កម្រិតថ្នាក់បានធ្វើតេសស្តង់ប្រចាំខែ តាមការណែនាំ<br>៣. ចំនួនសិស្សគ្រប់កម្រិតថ្នាក់បានធ្វើតេស្តស្តង់ដាដំណាច់ឆមាស តាមការណែនាំ |
| **គ លទ្ធផលការងារប្រជុំពិនិត្យតាមដាន៖** *ប្រចាំខែ និងត្រីមាស* | ១. ចំនួនខែ ដែលនាយកសាលាបានដឹកនាំ និងគ្រប់គ្រងការប្រជុំពិនិត្យតាមដានប្រចាំខែ.<br>២. ចំនួនត្រីមាស ដែលគណៈកម្មការគ្រប់គ្រងសាលារៀនបានដឹកនាំប្រជុំពិនិត្យតាមដានប្រចាំត្រីមាស ដែលត្រូវការជួយលើការចាត់ចែង គ្រប់គ្រង និងបច្ចេកទេសប្រជុំពីគណៈនាយកដោយផ្ទាល់ (បញ្ជាក់: ប្រសិនគណៈនាយកមិនចាត់ចែងនិងរៀបចំទេ គណៈកម្មការគ្រប់គ្រងមឹងមិនអាចដឹកនាំប្រជុំពិនិត្យតាមដានប្រចាំត្រីមាសបានទេ ) |
| **ឃ. លទ្ធផលការងារអធិការកិច្ច៖** *ការបង្រៀនរបស់គ្រូមុខវិជ្ជា និងការគ្រប់គ្រងរដ្ឋបាលថ្នាក់រៀនរបស់គ្រូបន្ទុកថ្នាក់* | ១. ចំនួនគ្រូមុខវិជ្ជា និងគ្រូបន្ទុកថ្នាក់បានធ្វើសំណើរសុំមកគណៈនាយក ដើម្បីទទួលយកទៅរៀបចំផែនការអធិកិច្ចប្រចាំឆ្នាំរបស់សាលារៀន អំពីការងារបង្រៀន និងការងារគ្រប់គ្រងរដ្ឋ បាលថ្នាក់រៀន<br>២. សាលារៀនមានផែនការអធិការកិច្ចប្រចាំឆ្នាំ ផ្អែកលើសំណើរសុំអធិការកិច្ចពីគ្រូមុខវិជ្ជា និងគ្រូបន្ទុកថ្នាក់<br>៣. ចំនួនមុខវិជ្ជា និងគ្រូបន្ទុកថ្នាក់ទទួលបានការធ្វើអធិការកិច្ច តាមត្រីមាស និងសរុបប្រចាំឆ្នាំ |

ឈ្មោះនាយិការងបច្ចេកទេសសាលា: ចាន់ ស្រីជា　　ហត្ថលេខា:...........................................................................

ឈ្មោះនាយកសាលារៀន.　ប្រាក់ វុទ្ធី　　ហត្ថលេខា:...............................

ធ្វើនៅថ្ងៃខែឆ្នាំ:.........................................................

# ការពិពណ៌នាអំពីតួនាទី និងមុខតំណែង នាយករងរដ្ឋបាល

(Job Description)

ឈ្មោះតួនាទី កុយ ធី នាយករងរដ្ឋបាល វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ព្រៃកតាទែន

រាយការណ៍ទៅ ប្រាក់ វុទ្ធី នាយក វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ព្រៃកតាទែន

ក **តួនាទី** ( Main purpose of the job )

នាយករងរដ្ឋបាលសាលារៀន ជួយដល់គ្រូបន្ទុកថ្នាក់ទាំងអស់ក្នុងសាលារៀន ឱ្យអាចធ្វើការនិងសម្របសម្រួលក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន បង្កើតគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដើម្បីអាចឱ្យថ្នាក់រៀនមានទំនាក់ទំនងគ្នាជាប្រចាំ រួមមានសិស្ស គ្រូមុខវិជ្ជា និងមាតាបិតាសិស្ស ដើម្បីបានជួយសិស្សរៀនយឺត និងកែលម្អថ្នាក់រៀន។ ក្នុងនោះដែរ ត្រូវជួយសាលារៀនឱ្យមានដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន សម្រាប់គ្រប់គ្រង ផែនការកែលម្អថ្នាក់រៀន និងសាលារៀន រួមជាមួយការធ្វើកិច្ចព្រមព្រៀង និងស្វ័យវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់គ្រូបង្រៀន និងគណៈនាយក។

ខ **គណនេយ្យភាពការងារ ឬកិច្ចការទទួលខុសត្រូវ** ( Key Accountabilities )

- ក. **លទ្ធផលការងារគណៈកម្មការគ្រប់គ្រងសាលារៀន៖** *រួមជាមួយគណៈកម្មការគ្រប់គ្រងថ្នាក់រៀន*
- ខ. **លទ្ធផលការងារផែនការកែលម្អសាលារៀន៖** *រួមជាមួយផែនការកែលម្អថ្នាក់រៀន*
- គ. **លទ្ធផលការងារកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ៖** *គ្រូបង្រៀន នាយករង និងនាយក*
- ឃ. **លទ្ធផលការងារស្វ័យវាយតម្លៃលទ្ធផលប្រចាំឆ្នាំ៖** *គ្រូបង្រៀន នាយករង និងនាយក*

គ **លទ្ធផលការបំពេញការងារ** ( Key performance objectives )

| **ផលសម្រេច** ( Output ) | **សូនាករ នៃការបំពេញការងារ** ( Key Performance Indicators ) |
|---|---|
| ក. លទ្ធផលការងារគណៈកម្មការគ្រប់គ្រងសាលារៀន *រួមជាមួយគណៈកម្មការគ្រប់គ្រងថ្នាក់រៀន* | ១. ចំនួនថ្នាក់រៀនមានបង្កើតគណៈកម្មការគ្រប់គ្រងថ្នាក់រៀន<br>២. សាលារៀនសម្របសម្រួលឱ្យក្រុមប្រឹក្សាកុមារយុវជន គ្រូបង្រៀន គណៈនាយក និង គណៈកម្មការគ្រប់គ្រងសាលារៀន បានចូលរួមធ្វើយុទ្ធនាការជ្រើសរើសគណៈកម្មការគ្រប់គ្រងសាលារៀន រួមមានសកម្មភាពបោះឆ្នោតជ្រើសរើស ឬការធ្វើបច្ចុប្បន្នភាពគណៈកម្មការគ្រប់គ្រងសាលារៀន តាមលំដាប់លំដោយនិងតាមការណែនាំ<br>៣. គណៈនាយកផ្សព្វផ្សាយលទ្ធផលជ្រើសរើស ឬបច្ចុប្បន្នភាពគណៈកម្មការគ្រប់គ្រងសាលារៀនដល់សិស្ស គ្រូបង្រៀន មាតាបិតា គណៈកម្មការគ្រប់គ្រងថ្នាក់រៀន និងអ្នកពាក់ព័ន្ធ<br>**សម្គាល់៖**<br>*សកម្មភាពសំខាន់ៗរបស់គណៈកម្មការគ្រប់គ្រងសាលារៀន៖ ក)ឯកភាព/អនុម័តឯកសារ គណៈកម្មការគ្រប់គ្រងថ្នាក់រៀន ខ)ឯកភាព/អនុម័តផែនការកែលម្អសាលារៀន គ)ដឹកនាំប្រជុំពិនិត្យតាមដានប្រចាំត្រីមាស និងបានដឹងឮលទ្ធផលអនុវត្តផែនការកែលម្អសាលារៀនប្រចាំត្រីមាស ពិសេសបានដឹងពីចំនួនសិស្សរៀនបោះបង់និងធ្លាក់ ឃ)ឯកភាព/អនុម័តកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់នាយក និងនាយករងសាលារៀន* |
| ខ. លទ្ធផលការងារផែនការកែលម្អសាលារៀន៖ *រួមជាមួយផែនការកែលម្អថ្នាក់រៀន* | ១. សាលារៀនមានផែនការកែលម្អសាលារៀន ដោយមានការចូលរួមពីសំណាក់សិស្ស ក្រុមប្រឹក្សាកុមារយុវជន គ្រូបង្រៀន គណៈនាយក គណៈកម្មការគ្រប់គ្រងសាលារៀន មណ្ឌលសុខភាព ប៉ុស្តិ៍នគរបាល និងអង្គភាពពាក់ព័ន្ធក្នុងភូមិសាស្ត្រសាលារៀន<br>២. គ្រូបង្រៀន និងសិស្សតាមភូមិដឹកនាំសកម្មភាពឆ្លងសេចក្តីព្រាងផែនការកែលម្អសាលារៀនជាមួយផ្ទះ អ្នកជិតខាងតាមភូមិនីមួយៗ<br>៣. ក្រុមប្រឹក្សាកុមារយុវជន គ្រូបង្រៀន គណៈនាយក និងគណៈកម្មការគ្រប់គ្រងសាលារៀន ផ្សព្វផ្សាយ និងបិតផ្សាយជាសាធារណៈផែនការកែលម្អសាលារៀន |

| | |
|---|---|
| **គ លទ្ធផលការងារកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ៖** *គ្រូបង្រៀន នាយករង និងនាយក* | ១. ចំនួនគ្រូបង្រៀន និងចំនួនគណៈនាយកបានធ្វើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ តាមលំដាប់លំដោយ និងតាមការណែនាំ។<br>២. ចំនួនកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំរបស់គ្រូបង្រៀន និងគណៈនាយក ដែលសាលារៀនបានផ្សព្វផ្សាយឱ្យសិស្ស មាតាបិតា គណៈកម្មការគ្រប់គ្រងថ្នាក់រៀន គណៈកម្មការគ្រប់គ្រងសាលារៀន អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធបានដឹងអំពីកិច្ចសន្យាសង្គមរបស់សាលារៀន |
| **ឃ. លទ្ធផលការងារស្វ័យវាយតម្លៃលទ្ធផលប្រចាំឆ្នាំ៖** *គ្រូបង្រៀន នាយករង និងនាយក* | ១. ចំនួនគ្រូបង្រៀន និងចំនួនគណៈនាយកបានធ្វើស្វ័យវាយតម្លៃលទ្ធផលប្រចាំឆ្នាំ<br>២. សាលារៀនបានផ្សព្វផ្សាយដល់សិស្ស មាតាបិតា គណៈកម្មការគ្រប់គ្រងថ្នាក់រៀន គណៈកម្មការគ្រប់គ្រងសាលារៀន អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ អំពីចំនួនគ្រូបង្រៀនសរុបក្នុងសាលារៀនជាប់ពិន្ទុការបំពេញភារកិច្ចវិជ្ជាជីវៈ ១ ២ ៣ ៤ និង៥<br>៣. សាលារៀនបានរៀបចំព្រឹត្តិការណ៍តាមរបៀបប្រពៃណីអ្នកមូលដ្ឋាន និងសាសនាដើម្បីលើកទឹកចិត្តដល់គ្រូបង្រៀន និងគណៈនាយកឆ្នើមប្រចាំឆ្នាំដែលទទួលបានពិន្ទុ៥ |

ឈ្មោះនាយករងសាលា:.................................................. ហត្ថលេខា:...............................................................................

ឈ្មោះនាយកសាលារៀន.................................................. ហត្ថលេខា:.................................

ធ្វើនៅថ្ងៃខែឆ្នាំ:..............................................................

# ការពិពណ៌នាអំពីតួនាទី និងមុខតំណែង គ្រូបន្ទុកថ្នាក់

(Job Description)

**ឈ្មោះតួនាទី** គ្រូបន្ទុកថ្នាក់ទី

**រាយការណ៍ទៅ កុយ ធី** នាយករងរដ្ឋបាល

**ក តួនាទី** ( Main purpose of the job )

គ្រូបន្ទុកថ្នាក់ជួយក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន ប្រមូលទិន្នន័យរដ្ឋបាលថ្នាក់រៀនប្រចាំខែ រួមមានទិន្នន័យលទ្ធផលសិក្សារបស់សិស្ស និងការបង្រៀនរបស់គ្រូមុខវិជ្ជាសម្រាប់រាយការណ៍បន្តទៅនាយករង ឬនាយកសាលា។ ដោយឡែកជួយក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន រៀបចំសកម្មភាព ប្រជុំប្រចាំខែជាមួយមាតាបិតាសិស្សអវត្តមាន និងសិស្សរៀនយឺត ដើម្បីផ្តល់ព័ត៌មានត្រឡប់ និងរួមគ្នារិះរកវិធានការបន្តនៅខែបន្ទាប់។ កិច្ចការនេះក្រុមសិស្សដែលទទួលបន្ទុកការប្រជុំប្រចាំខែជាមួយមាតាបិតាសិស្ស ជាអ្នកចាត់ចែងការប្រជុំ ដោយមានជម្រើសផ្សេងៗដូចជា៖ (១)ជួបគ្នាផ្ទាល់នៅថ្នាក់រៀន (២)ជួបគ្នាផ្ទាល់នៅសហគមន៍ និង(៣)ជួបគ្នាផ្ទាល់តាមទូរស័ព្ទ ឬអនឡាញ អាស្រ័យលើជម្រើសរបស់មាតាបិតាសិស្សអវត្តមាន និងរៀនយឺត។

**ខ គណនេយ្យភាពការងារ ឬកិច្ចការទទួលខុសត្រូវ** ( Key Accountabilities )

- ក. **បង្កើតក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន៖** *រួមជាមួយកុមារក្រុមតូចៗតម្រូវតាមចំនួនកិច្ចការរដ្ឋបាលថ្នាក់រៀន*
- ខ. **ជួយសិស្សម្នាក់ៗ ឱ្យធ្វើផែនការសិក្សាឆ្នាំ និងរបាយការណ៍សិក្សាប្រចាំខែ៖** *ផ្សារភ្ជាប់ជាមួយផែនការបង្រៀនរបស់គ្រូមុខវិជ្ជា*
- គ. **បង្កើតគណៈកម្មការគ្រប់គ្រងថ្នាក់រៀន៖** *ទាក់ទាញចំណាប់អារម្មណ៍មាតាបិតា និងសហគមន៍ជួយសិស្ស ជួយគ្រូ និងបរិស្ថានថ្នាក់រៀន*
- ឃ. **លប់បំបាត់អំពើហឹង្សា៖** *នៅថ្នាក់រៀន សាលារៀន និងនៅក្នុងគ្រួសារសិស្ស*
- ង. **សរសេរករណីសិក្សាសិស្ស៖** *ផ្តោតលើមុខសញ្ញាកុមារី (អាចជាសិស្សពិការ រងអំពើហឹង្សា រៀនយឺត បោះបង់ការសិក្សា....)*

**គ លទ្ធផលការបំពេញការងារ** ( Key performance objectives )

| **ផលសម្រេច** ( Output ) | **សូនាករ នៃការបំពេញការងារ** ( Key Performance Indicators ) |
|---|---|
| **ក.បង្កើតក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន** *(សម្រាប់ដឹកនាំគ្រប់គ្រងទិន្នន័យរដ្ឋបាលថ្នាក់រៀន រួមជាមួយទិន្នន័យអំពើហឹង្សា និងទិន្នន័យលទ្ធផលការរៀនរបស់សិស្សម្នាក់ៗ និងការបង្រៀនរបស់គ្រូម្នាក់ៗ)* | ១. បានបង្កើតក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន (តាមរយៈការបោះឆ្នោត)<br>២. បានបង្កើតក្រុមតូចៗសម្រាប់ទទួលកត់ត្រា និងសរុបទិន្នន័យជាប្រចាំថ្ងៃ សប្តាហ៍ ខែ<br>៣. បានជួយក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀនសរុប និងរាយការណ៍ទិន្នន័យរដ្ឋបាលថ្នាក់រៀនប្រចាំខែទៅគ្រូបន្ទុកថ្នាក់ និងអ្នកពាក់ព័ន្ធ<br>៤. បានប្រជុំប្រចាំខែជាមួយមាតាបិតាមានកូនអវត្តមាន រៀនយឺត និងបម្រុងបោះបង់ |
| **ខ. ជួយសិស្សម្នាក់ៗ ឱ្យធ្វើផែនការសិក្សាឆ្នាំ និងរបាយការណ៍សិក្សាប្រចាំខែ** *(ផ្អែកលើលទ្ធផលតេស្តស្តង់ដាដើមឆ្នាំ)* | ១. ចំនួនសិស្សមានផែនការសិក្សាឆ្នាំ<br>២. ចំនួនសិស្សបានធ្វើរបាយការណ៍សិក្សាប្រចាំខែ ផ្អែកលើទិន្នន័យឆ្នាំ<br>៣. បានផ្តល់ព័តលទ្ធផលសិក្សាសិស្សម្នាក់ៗប្រចាំខែ ប្រៀបធៀបផែនការសិក្សាឆ្នាំរបស់សិស្ស ទៅឱ្យមាតាបិតាសិស្សបានដឹងប្រចាំខែ |
| **គ. បង្កើតគណៈកម្មការគ្រប់គ្រងថ្នាក់រៀន** *(ផ្តោតលើលទ្ធផលសិក្សារបស់សិស្សម្នាក់ៗ និងកែលម្អថ្នាក់រៀន)* | ១. មានគណៈកម្មការគ្រប់គ្រងថ្នាក់រៀន និងបានផ្សព្វផ្សាយដល់សិស្ស គ្រូមុខវិជ្ជា និងមាតាបិតាសិស្សដែលជាសមាជិកទាំងអស់បានដឹង<br>២. គណៈកម្មការគ្រប់គ្រងថ្នាក់រៀនមានផែនការសកម្មភាពឆ្នាំ |

| | |
|---|---|
| **ឃ. លប់បំបាត់អំពើហឹង្សា**<br>*(នៅថ្នាក់រៀន សាលារៀន និងគ្រួសារសិស្ស)* | ១. បានសម្ភាសន៍សិស្សទាំងអស់ក្នុងថ្នាក់ អំពីស្ថានភាពអំពហឹង្សា (នៅដើមឆ្នាំសិក្សា)<br>២. បានរៀបចំឱ្យមានសំណូមពរៈ<br>- សំណូមពរសិស្ស ទៅគ្រូបង្រៀន និងមាតាបិតា<br>- សំណូមពរគ្រូបង្រៀន ទៅសិស្ស និងមាតាបិតា<br>- សំណូមពរមាតាបិតា ទៅគ្រូបង្រៀន និងសិស្ស<br>៣. បានសម្ភាសន៍សិស្សទាំងអស់ក្នុងថ្នាក់ អំពីស្ថានភាពអំពហឹង្សា (នៅដំណាច់ឆ្នាំសិក្សា) |
| **ង. សរសេរកំណើសិក្សាសិស្ស**<br>*(ផ្តោតលើសិស្សស្រី ពិការ ជនជាតិដើមភាគតិច រៀនយឺត មកពីគ្រួសារជួបការលំបាកមករៀនយឺត អវត្តមានច្រើន បម្រុងបោះបង់ការសិក្សា ឬ បានបោះបង់ការសិក្សា)* | ១. បានជ្រើសរើសសិស្សសម្រាប់សរសេរកំណើសិក្សា (នៅដើមឆ្នាំសិក្សា)<br>២. បានសរសេរកំណើសិក្សាសិស្សបានយ៉ាងតិច១នាក់ ក្នុងមួយឆ្នាំសិក្សា ដោយសហការណ៍ជាមួយគ្រូមុខវិជ្ជា និងក្រុមប្រឹក្សាកុមារយុវជនថ្នាក់រៀន |

ឈ្មោះនាយករងវេជ្ជបាកសាលាៈ.  កុយ  ធី  ហត្ថលេខាៈ...........................................................................

ឈ្មោះនាយកសាលារៀន.  ប្រាក់  វុទ្ធី  ហត្ថលេខាៈ................................

ធ្វើនៅថ្ងៃខែឆ្នាំៈ..............................................................

# ការពិពណ៌នាអំពីតួនាទី និងមុខតំណែង គ្រូមុខជ្ជា

(Job Description)

**ឈ្មោះតួនាទី** គ្រូបង្រៀនមុខវិជ្ជា ..................... ..............ថ្នាក់ទី

**រាយការណ៍ទៅ ចាន់ ស្រីជា** នាយិការងបច្ចេកទេស

**ក តួនាទី** ( Main purpose of the job )

គ្រូមុខវិជ្ជាសហការណ៍ជាមួយគ្រូមុខវិជ្ជាផ្សេងទៀត ដែលបង្រៀនក្នុងថ្នាក់ជាមួយគ្នា ដើម្បីជួយសិស្សក្នុងថ្នាក់រៀនសម្រេចបានលទ្ធផលដូចការរំពឹងទុកដែលបានកំណត់ក្នុងផែនការបង្រៀន៣ឆ្នាំ ១ឆ្នាំ និង៣ខែ។ ដូច្នេះកិច្ចការសំខាន់ៗមាន ការធ្វើផែនការបង្រៀន ការរៀបចំគម្រោងបង្រៀនមួយមេរៀន និងការរៀបចំគម្រោងបង្រៀនចម្រុះមុខវិជ្ជា។

**ខ គណនេយ្យភាពការងារ ឬកិច្ចការទទួលខុសត្រូវ** ( Key Accountabilities )

ក. ធ្វើបំណែងចែកកម្មវិធីសិក្សាសម្រាប់បង្រៀនប្រចាំសប្តាហ៍៖ *ផ្អែកលើកម្មវិធីសិក្សាលម្អិត និងសៀវភៅសិក្សាគោល*

ខ. ធ្វើផែនការ និងរបាយការណ៍បង្រៀន៣ឆ្នាំ និង១ឆ្នាំ៖ *ផ្អែកលើលទ្ធផលតេស្តស្តង់ដាដើមឆ្នាំ*

គ. ធ្វើផែនការ និងរបាយការណ៍បង្រៀនរៀងរាល់៣ខែ៖ *ផ្អែកលើផែនការបង្រៀន៣ឆ្នាំ ១ឆ្នាំ និង៣ខែ*

ឃ. រៀបចំគម្រោងបង្រៀនមួយមេរៀនមានច្រើនម៉ោងសិក្សា៖ *ផ្តោតលើចំណេះដឹងមុខវិជ្ជា*

ង. រៀបចំគម្រោងបង្រៀនចម្រុះមុខវិជ្ជា៖ *ផ្តោតលើបំណិនរកចំណូលផ្សារភ្ជាប់បំណិនជីវិត និងបំណិនការងារ*

**គ លទ្ធផលការបំពេញការងារ** ( Key performance objectives )

| **ផលសម្រេច** ( Output ) | **សូនាករ នៃការបំពេញការងារ** ( Key Performance Indicators ) |
|---|---|
| ក.ធ្វើបំណែងចែកកម្មវិធីសិក្សាបង្រៀនប្រចាំសប្តាហ៍សម្រាប់ឆ្នាំសិក្សា<br>*( ផ្អែកលើកម្មវិធីសិក្សាលម្អិតអប់រំមូលដ្ឋានចំណេះទូទៅ )* | ១. មានបំបែងចែកកម្មវិធីសិក្សាសម្រាប់បង្រៀនប្រចាំសប្តាហ៍តាមខែ (ធ្វើរួមគ្នាជាមួយក្រុមបច្ចេកទេស)<br>២. បានផ្សព្វផ្សាយបំបែងចែកកម្មវិធីសិក្សាសម្រាប់បង្រៀនប្រចាំសប្តាហ៍តាមខែ ទៅសិស្ស និងមាតាសិស្សទាំងអស់ |
| ខ. ធ្វើផែនការនិងរបាយការណ៍បង្រៀន៣ឆ្នាំ និង១ឆ្នាំ<br>*( ផ្អែកលើលទ្ធផលតេស្តស្តង់ដាដើមឆ្នាំ )* | ១. មានផែនការបង្រៀន៣ឆ្នាំ និង១ឆ្នាំ<br>២. មានរបាយការណ៍បង្រៀន៣ឆ្នាំ និង១ឆ្នាំ<br>៣ បានផ្សព្វផ្សាយផែនការបង្រៀនទៅសិស្ស និងមាតាសិស្សទាំងអស់ |
| គ. ធ្វើផែនការនិងរបាយការណ៍បង្រៀនរៀងរាល់៣ខែ<br>*( ផ្អែកលើផែនការបង្រៀន១ឆ្នាំ និង៣ឆ្នាំ )* | ១. មានផែនការបង្រៀនរៀងរាល់៣ខែ<br>២. មានរបាយការណ៍បង្រៀនរៀងរាល់៣ខែ<br>៣ បានផ្សព្វផ្សាយផែនការបង្រៀនទៅសិស្ស និងមាតាសិស្សទាំងអស់ |
| ឃ. រៀបចំគម្រោងបង្រៀនមួយមេរៀនមានច្រើនម៉ោងសិក្សា<br>*( ផ្តោតលើចំណេះដឹងមុខវិជ្ជា៖ ឱ្យបានគ្រប់មេរៀនទាំងអស់ ដែលមានក្នុងកម្មវិធីសិក្សាលម្អិតរួមជាមួយសៀវភៅសិក្សាគោល )* | ១. មានគម្រោងបង្រៀនមួយមេរៀនច្រើនម៉ោងសិក្សា ដោយសន្សំជារៀងរាល់ឆ្នាំ (ធ្វើរួមគ្នាជាមួយក្រុមបច្ចេកទេស)<br>២. មានធ្វើបច្ចុប្បន្នភាពគម្រោងបង្រៀនមួយមេរៀនច្រើនម៉ោងសិក្សា (ដោយធ្វើរួមគ្នាជាមួយក្រុមបច្ចេកទេស) |

| | |
|---|---|
| **ង. រៀបចំគម្រោងបង្រៀនចម្រុះមុខវិជ្ជា** *(ផ្ដោតលើបំណិនជីវិត និងបំណិនការងារ៖តាមរយៈកិច្ចការគម្រោងដោយផ្សារភ្ជាប់បំណិនរកចំណូល)* | ១. មានគម្រោងបង្រៀនចម្រុះមុខវិជ្ជា ផ្អែកលើផែនការវិនិយោគរបស់ក្រុមសិស្ស និងដោយសន្សំជារៀងរាល់ឆ្នាំ (ធ្វើរួមគ្នាជាមួយក្រុមបច្ចេកទេស)<br>២. ចំនួនសិស្សបានធ្វើរបាយការណ៍ស្រាវជ្រាវ តាមរយៈសកម្មភាពគម្រោង |

ឈ្មោះនាយិការងបច្ចេកទេសសាលា:. ចាន់ ស្រីជា ហត្ថលេខា:............................................

ឈ្មោះនាយកសាលារៀន. ប្រាក់ វុទ្ធី ហត្ថលេខា:................................

ធ្វើនៅថ្ងៃខែឆ្នាំ:..............................................................